**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ:...៤០...សសរ...**

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេស ដើម្បីស៊ើបអង្កេត លើករណីមិនប្រក្រតីក្នុងការផ្តល់វិញ្ញាបនប័ត្រចុះបញ្ជីយន្តហោះ និងវិញ្ញាបនប័ត្រត្រួតពិនិត្យលទ្ធភាពហោះហើរ

********

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦,០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦,២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមតំរូវការចាំបាច់

## សម្រេច

**ប្រការ ១ :** បង្កើតក្រុមការងារបច្ចេកទេសមួយ ដើម្បីធ្វើការស៊ើបអង្កេតលើករណីមិនប្រក្រតី ក្នុងការផ្តល់វិញ្ញាបនប័ត្រចុះបញ្ជីយន្តហោះ និងវិញ្ញាបនប័ត្រត្រួតពិនិត្យលទ្ធភាពហោះហើរ ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **ខាវ អួន** អគ្គនាយក នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធាន
២- លោក **ឆាន់ ចាន់ឡារ័ត្ន** អគ្គនាយករងនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុប្រធាន
៣- លោក **កែច ស៊ីថន** ប្រធាននាយកដ្ឋានប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ សមាជិក
៥- លោក **សេង ទាំន្លី** ប្រធាននាយកដ្ឋានរដ្ឋបាលបុគ្គលិក សមាជិក

**ប្រការ ២:** ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

- សហការជាមួយនាយកដ្ឋានផ្ទៃក្នុង នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីធ្វើការស៊ើបអង្កេតលើករណីមិនប្រក្រតី ក្នុងការផ្តល់វិញ្ញាបនប័ត្រចុះបញ្ជីយន្តហោះ និងវិញ្ញាបនប័ត្រត្រួតពិនិត្យលទ្ធភាពហោះហើរ។
- ធ្វើរបាយការណ៍ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពី លទ្ធផលនៃការស៊ើបអង្កេតករណី ខាងលើនេះ ដើម្បីជូនជ្រាប និងផ្តល់ការណែនាំ។
- ក្នុងកំឡុងពេលកំពុងដំណើរការស៊ើបអង្កេត ប្រគល់ភារកិច្ច ផ្នែកត្រួតពិនិត្យលទ្ធភាពហោះហើរ ជូនលោក **កែច ស៊ីថន** ប្រធាននាយកដ្ឋានប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ ជាអ្នកគ្រប់គ្រង និងចាត់ចែងដោយផ្ទាល់។

**ប្រការ ៣:** រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវទទួលអនុវត្ត សេចក្តីសំរេចអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញាឆ្នាំ ២០០៥*

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

**ចម្លងជូន :**
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ✓
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ញឹក ប៊ុនឆៃ
-ដូចប្រការ ៣
-ឯកសារ-កាលប្បវត្តិ